ក្រុមប្រឹក្សាធម្មនុញ្ញ
ចេញនៅថ្ងៃទី 25 10
ឆ្នាំ 13 ម៉ោង 9h
ចុះឈ្មោះលេខ 0730

22-10-13
1415

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤.៥.៧.អសប.ប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គលេខាធិការដ្ឋាន
លេខ 294
ចុះថ្ងៃទី 04.11 ឆ្នាំ 2013
ម៉ោង 10:25

អនុក្រឹត្យ

ស្តីពី

ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០១៤

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/ ០៨០៥/៣៥៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត ០៤១១/៣៤០ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមុខតំណែងសមាសភាពថ្នាក់ដឹកនាំមួយចំនួន នៃ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-បានឃើញ អនុក្រឹត្យលេខ១៨៦ អនក្រ.បក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ១៥៦ អនក្រ.បក ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១៣។

-បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលវេលាបម្រើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

-បានឃើញ អនុក្រឹត្យលេខ ២៥ អនក្រ/បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

ស ៤ ៦ ម ច

មាត្រា ១.-

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជា បានឈប់សម្រាកការងារ ឆ្នាំ ២០១៤ តាមប្រតិទិន ដូចខាងក្រោម :

- ថ្ងៃទី ០១	មករា	ទិវាចូលឆ្នាំសកល	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០៧	មករា	ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៤	កុម្ភៈ	ពិធីបុណ្យមាឃបូជា	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០៨	មីនា	ទិវានារីអន្តរជាតិ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៤-១៥-១៦	មេសា	ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ	សម្រាក០៣ ថ្ងៃ
- ថ្ងៃទី ០១	ឧសភា	ទិវាពលកម្មអន្តរជាតិ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៣	ឧសភា	ពិធីបុណ្យវិសាខបូជា	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៣-១៤-១៥	ឧសភា	ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី**	សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ១៧	ឧសភា	ព្រះរាជពិធីច្រត់ព្រះនង្គ័ល	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០១	មិថុនា	ទិវាកុមារអន្តរជាតិ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៨	មិថុនា	ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម**សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតា នរោត្តម មុនិនាថ សីហនុ**	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២២-២៣-២៤	កញ្ញា	ពិធីបុណ្យភ្ជុំបិណ្ឌ	សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ២៤	កញ្ញា	ទិវាប្រកាសរដ្ឋធម្មនុញ្ញ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៥	តុលា	ទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ**ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះឥរាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"**	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២៣	តុលា	ទិវារំលឹកខួបនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២៩	តុលា	ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០៥-០៦-០៧	វិច្ឆិកា	ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង សំពះព្រះខែ អកអំបុក	សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ០៩	វិច្ឆិកា	ពិធីបុណ្យឯករាជ្យជាតិ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១០	ធ្នូ	ទិវាសិទ្ធិមនុស្សអន្តរជាតិ	សម្រាក ០១ ថ្ងៃ

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី និងខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខ:.....១០១.....ស.ន.ក

បានឋតចម្លងត្រឹមត្រូវតាមច្បាប់ដើម

អគ្គភាពថ្នាក់កណ្តាល ដើម្បីផ្សព្វផ្សាយ និងអនុវត្ត។

រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៣

អគ្គលេខាធិការរដ្ឋបាល និងហិរញ្ញវត្ថុ

វេជ្ជ.យក់ សម្ផស្សី